00290328

E26

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT O...
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 03 / 2009
ម៉ោង (Time/Heure): 10:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ | ២០ ខែ មីនា ឆ្នាំ ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

| | |
|---|---|
| គង់ ពិសី | ទី ស្រ៊ីនណា |
| ហុង គីមសួន | Piere Olivier SUR |
| យុង ផានិត | Alain WERNER |
| គីម ម៉េងឃី | Brianne McGONIGLE |
| ម៉ុច សុវណ្ណារី | Annie DELAHAIE |
| Silke STUDZINSKY | Elizabeth RABESANDRATANA |
| Martine JACQUIN | Karim KHAN |
| Philippe CANONNE | |

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") យោងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូង លើសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង ទាក់ទងនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ (ឯកសារ E15)។

ដើម្បីឱ្យគ្រប់ភាគីទាំងអស់ត្រៀមរៀបចំបានល្អប្រកបដោយប្រសិទ្ធិភាព អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់នូវព័ត៌មានមួយចំនួនដូចខាងក្រោមទាក់ទងនិងដំណើរការនីតិវិធី៖

១. **បើកសវនាការ** : ប្រធានប្រកាសបើកសវនាការលើអង្គសេចក្តី (វិធាន៨៩ ស្ទួន(១))។

២. **សំណួរទៅកាន់ជនជាប់ចោទ** : ប្រធាននឹងស្នើជនជាប់ចោទឱ្យធ្វើការបញ្ជាក់នូវជីវប្រវត្តិ និងប្រាប់នូវសិទ្ធិរបស់គាត់ដល់គាត់ ដោយផ្អែកតាមវិធាន ២១ (១)(ឃ) (វិធាន ៩០)។

៣. **ការវិភាគពីអង្គហេតុ និងបទចោទ** : ប្រធាននឹងបង្គាប់ឱ្យក្រឡាបញ្ជីអាននូវការវិភាគអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបទចោទប្រឆាំងនឹងជនជាប់ចោទ (កថាខណ្ឌទី១០ ដល់ទី១៦២ នៃដីកាដំណោះស្រាយ D99 រួមទាំងកថាខណ្ឌទី១៥២-១៥៣ដែលបានធ្វើការកែប្រែ ដើម្បីឱ្យស្របទៅតាមដីកាសម្រេចលេខ D99/3/42 របស់អង្គបុរេជំនុំជម្រះ)។

៤. **ការធ្វើសេចក្តីសន្និដ្ឋាន** : ប្រធាននឹងស្នើសហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ (វិធាន ៨៩ ស្ទួន(២)) ហើយមេធាវីការពារក្តីអាចធ្វើសន្និដ្ឋានតប ប្រសិនបើខ្លួនមានបំណង ។

រយៈពេលសរុបសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា គឺ **២ម៉ោង** ហើយជនជាប់ចោទឬមេធាវីរបស់គាត់ នឹងមានរយៈពេល**២ម៉ោង** ដើម្បីធ្វើសេចក្តីសន្និដ្ឋានតប ប្រសិនបើមាន។

2/6
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

អង្គជំនុំជម្រះសាលាដំបូងអាចបញ្ឈប់ការនិយាយរបស់ភាគី ប៉ុន្តែធ្វើឡើងក្នុងករណីដែលមានមូលហេតុជាក់លាក់ ។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនទទួលនូវការដេញដោលពីបុគ្គលណាមួយ ឬភាគីណាមួយឡើយទាក់ទងទៅនឹងការធ្វើសេចក្តីសន្និដ្ឋាននេះ ។

**៥. ការព្រមព្រៀងទៅលើអង្គហេតុ :**
ប្រធាននឹងស្នើឱ្យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីបង្ហាញអង្គហេតុដែលបានព្រមព្រៀង ប្រសិនបើមាន។

មតិយោបល់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យធ្វើទេទាក់ទងនិងចំណុចនេះ ។

៦. **សំណើ :** រាល់សំណើដែលភាគីទាំងអស់បានលើកឡើងនឹងត្រូវយកមកពិភាក្សានៅដំណាក់កាលនេះ។

៧. **លក្ខណៈនៃការសួរសំណួរ :** ប្រធានប្រាប់ដល់ភាគីទាំងអស់អំពីលក្ខណៈនៃការសួរសំណួរដល់ជនជាប់ចោទ និងសាក្សីទាំងអស់ ដូចដែលបានពណ៌នាខាងក្រោម៖

៨. **មតិលើកឡើងដោយជនជាប់ចោទ :** ប្រសិនបើជនជាប់ចោទស្នើសុំ ប្រធាននឹងផ្តល់ឱកាសដល់គាត់ដើម្បីធ្វើការបញ្ចេញមតិទាក់ទងទៅនិងការចោទប្រកាន់ប្រឆាំងនឹងគាត់ ។ ប្រធាននឹងប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ ឱកាសដែលផ្តល់ជូននេះគឺសម្រាប់តែការឆ្លើយតបទៅនឹងការចោទប្រកាន់តែប៉ុណ្ណោះ ។ វាមិនមែនជាពេលវេលាសម្រាប់ធ្វើការឆ្លើយតបដែលមានភាពលំអិតនោះទេ ។ នៅក្នុងដំណាក់កាលនេះនឹងមិនអនុញ្ញាតិឱ្យមានការសួរសំណួរពីភាគីណាមួយឡើយ។

**៩. ការសួរសំណួរដល់ជនជាប់ចោទ និងការស្តាប់ចម្លើយសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ :**

<u>លំដាប់លំដោយនៃការសួរសំណួរ :</u>

៩.១ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង នឹងសួរសំណួរដល់ជនជាប់ចោទមុនគេ ហើយបន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលពាក់ព័ន្ធតាមលំដាប់ដែល



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

ខ្លួនគិតថាមានប្រយោជន៍ទៅតាមអង្គហេតុនីមួយៗ។ អង្គជំនុំជម្រះនឹងព្យាយាមអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោមនេះ ៖

- បញ្ហាទាក់ទងទៅនិងមន្ទីរ ម-១៣
- ការបង្កើតមន្ទីរ ស-២១ និងគុកតាខ្មៅ
- ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១
- ជម្លោះប្រដាប់អាវុធ
- ប្រតិបត្តិការរបស់មន្ទីរ ស-២១ រួមបញ្ចូលទាំងជើងឯក
- ការបង្កើត និងប្រតិបត្តិការរបស់មន្ទីរ ស-២៤
- បញ្ហាទាក់ទងទៅនឹងអត្តចារិករបស់ជនជាប់ចោទ។

<u>ការសួរសំណួរដល់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ:</u> បន្ទាប់ពីជនជាប់ចោទត្រូវបានគេសួរសំណួរអំពីអង្គហេតុជាក់លាក់រួចហើយ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ដែលពាក់ព័ន្ធនឹងឡើងធ្វើសេចក្តីថ្លែង ឬធ្វើសក្ខីកម្មទៅតាមអង្គហេតុនីមួយៗ។ លំដាប់នៃការសួរសំនួរនេះនឹងត្រូវយកមកអនុវត្តចំពោះការសួរទៅតាមអង្គហេតុផ្សេងទៀត ។

៩.២ <u>ការសួរសំណួរដោយភាគី :</u>

- ភាគីទាំងអស់ មានដូចជា សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី ក្រោយពេលចៅក្រមសួរចប់ នឹងមានឱកាសសួរសំណួរបន្ថែមដល់ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីឬ សាក្សី ឬអ្នកជំនាញ ទៅតាមអង្គហេតុ ដែលបានកំណត់ខាងលើ។
- មិនអនុញ្ញាតឱ្យសួរសំណួរដដែលៗ
- ជនជាប់ចោទអាចត្រូវបានសួរតទល់ទៅនឹងឯកសារទាំងឡាយបាន លុះត្រាតែឯកសារនោះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយគោរពទៅតាមវិធាន ៨៧(២) និង (៣)។ ជនជាប់ចោទមិនត្រូវបានសួរតទល់ជាមួយនឹងចម្លើយរបស់សាក្សីដែលមិនទាន់បានស្តាប់ចម្លើយនោះទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C

E26

មានការលើកលែងក្នុងករណីនេះ គឺប្រសិនបើសាក្សីនោះស្លាប់ ឬក៏មិនអាចផ្តល់ចម្លើយបានដោយមានហេតុផលណាមួយផ្សេងទៀត ហើយបន្ទាប់ពីភាគីទាំងអស់បានយល់ព្រមឲ្យមានការអានចម្លើយសាក្សីនោះ។

- ការសួរតទល់ជាមួយនិងចម្លើយរបស់សាក្សីនានា ដែលនឹងត្រូវមកធ្វើសក្ខីកម្មក្នុងពេលសវនាការ នឹងត្រូវធ្វើឡើងក្នុងអំឡុងពេលនៃការស្តាប់ចម្លើយសាក្សីនោះ។

## ១០. ការបង្ហាញភស្តុតាងផ្សេងទៀត

អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាទៅលើភស្តុតាងដែលបានដាក់ជូនខ្លួនពិនិត្យដោយអនុលោមតាមវិធាន ៨៧(២ និង ៣) នៅពេលណាខ្លួនយល់ថាមានសារៈប្រយោជន៍ក្នុងការធ្វើការពិចារណា។

## ១១. ការប៉ាន់ប្រមាណថិរៈវេលា[1] :

- ចំណុចទី០១ ដល់ ០៨ (ថ្ងៃទី៣០ ខែមីនា-ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩)
- ការសួរជនជាប់ចោទ លើបញ្ហាទាក់ទងនិងមន្ទីរ ម-១៣ (ថ្ងៃទី០៦-០៧ ខែមេសា ឆ្នាំ២០០៩)
- ការសួរសាក្សីលើបញ្ហាទាក់ទងទៅនឹងមន្ទីរ ម-១៣ (ចាប់ផ្តើមពីសាក្សី KW-32, KW-31 និង KW-30 និងសាក្សី TC1 ដែលនឹងត្រូវផ្តល់សក្ខីកម្មនៅថ្ងៃទី ០៨ ឬ ០៩ ខែមេសា)
- ថ្ងៃទី១៣-១៦ ខែមេសា : សម្រាក
- ការសួរជនជាប់ចោទ ទាក់ទងនឹងការបង្កើត ស២១
- ការសួរដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលជាប់ទាក់ទងទៅនឹងការបង្កើតមន្ទីរ ស-២១

[1] ភាគីទាំងអស់គួរតែមានការត្រៀមលក្ខណៈជាមុន ដើម្បីសម្របទៅនឹងការប្រែប្រួលក្នុងការប៉ាន់ប្រមាណ នៃការកំណត់ពេលវេលា នៃការសួរសំណួរដល់ជនជាប់ចោទ ឬសាក្សីនានា។ ការកំណត់កាលបរិច្ឆេទអាចខ្លីជាង ឬយូរជាងពេលវេលាដែលបានកំណត់។





TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

00290333



- ការសួរជនជាប់ចោទទាក់ទងនឹង ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១
- ការសួរដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១

ព័ត៌មានបន្ថែមទាក់ទងទៅនិងការកំណត់នូវនីតិវិធីដំណាក់កាលបន្ទាប់ នឹងត្រូវផ្តល់ជូនមិនឲ្យហួសពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ ។

១២. **ការមានវត្តមានរបស់មេធាវី** : អង្គជំនុំជម្រះសាលាដំបូងរំពឹងថាមេធាវីទាំងអស់នឹងទទួលបានការជូនដំណឹងគ្រប់គ្រាន់ នឹងបានរៀបចំរួចជាស្រេចដើម្បីចូលរួមដំណើរការនីតិវិធីក្នុងនាមកូនក្តីរបស់ខ្លួន។ ក្នុងករណីដែលមានតែមេធាវីម្នាក់ធ្វើជាតំណាង ឬការពារក្តីដល់ភាគីនីមួយៗមានវត្តមាន នោះនីតិវិធីនឹងប្រព្រឹត្តិទៅជាធម្មតា។

១៣. **ការផ្សាយបន្តផ្ទាល់** : ជាគោលការណ៍ទូទៅ ការផ្សាយបន្តផ្ទាល់អំពីកិច្ចដំណើរការនីតិវិធីនឹងត្រូវបានអនុញ្ញាត្តិដល់ប្រព័ន្ធសារព័ត៌មាន លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអង្គជំនុំជម្រះសាលាដំបូង។ សូមឲ្យភាគីទាំងអស់មាននូវការប្រុងប្រយ័ត្នដើម្បីជៀសវាងការលេចចេញនូវព័ត៌មានដែលមានភាពសម្ងាត់ ឬព័ត៌មានដែលមានលក្ខណៈឯកជនដូចជាព័ត៌មាន ស្តីពីអត្តសញ្ញាណ របស់សាក្សីដែលត្រូវបានការពារ។

ភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

និល ណុន